អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## នាយករដ្ឋមន្ត្រីនូវែលហ្សេឡង់ប្រកាសសន្យាផ្តល់ជំនួយថវិកាបន្ថែម ចំនួន ២០០ ០០០ ដុល្លារនូវែលហ្សេឡង់ ដល់ អ.វ.ត.ក

នាយករដ្ឋមន្ត្រីនូវែលហ្សេឡង់ ឯកឧត្តម ចន ឃី បានប្រកាសនៅក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅព្រឹកនេះ សន្យាផ្តល់ជំនួយថ្មីបន្ថែមដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នូវថវិកាចំនួន ២០០ ០០០ ដុល្លារនូវែលហ្សេឡង់។

ឯកឧត្តមនាយករដ្ឋមន្ត្រីបានដឹកនាំគណៈប្រតិភូចំនួន៨រូបមកធ្វើទស្សនកិច្ចនៅ អ.វ.ត.ក នៅមុនពេលបញ្ចប់ដំណើរទស្សនកិច្ចជាផ្លូវការរបស់ឯកឧត្តមមកកាន់កម្ពុជាដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន។ នេះគឺជាលើកទី១ហើយ ដែល អ.វ.ត.ក បានទទួលដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋាភិបាល។

ឯកឧត្តម ចន ឃី ប្រកាសអំពីជំនួយថ្មីនេះនៅក្នុងជំនួបពិភាក្សាជាមួយប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក ឯកឧត្តម ក្រាញ់ តូនី និងលោកឃ្នុត រ៉ូសិនហាក ជាអនុប្រធាន។ ឯកឧត្តម បានមានប្រសាសន៍ថា "នូវែលហ្សេឡង់នឹងបន្តគាំទ្រសាលាក្តីខ្មែរក្រហម ដើម្បីឲ្យតុលាការនេះអាចបញ្ចប់កិច្ចការរបស់ខ្លួនក្នុងការជំនុំជម្រះក្តីអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម"។

ក្នុងឱកាសនេះដែរ ឯកឧត្តមនាយករដ្ឋមន្ត្រីនូវែលហ្សេឡង់ ក៏បានជួបជាមួយលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក និងលោកស្រីចៅក្រម ស៊ីលវៀរ ខាតវ៉ាយ ដែលជាជនជាតិនូវែលហ្សេឡង់ និងបានទស្សនាសាលសវនាការផងដែរ។

ឆ្លើយតបនឹងជំនួយសប្បុរសនេះ ឯកឧត្តម ក្រាញ់ តូនី និងលោក ឃ្នុតរ៉ូសិនយក បានថ្លែងថា "យើងសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនូវែលហ្សេឡង់ដែលបន្តផ្តល់ជំនួយថវិកាដល់ អ.វ.ត.ក"។

ប្រទេសនូវែលហ្សេឡង់បានផ្តល់ការគាំទ្រចំពោះ អ.វ.ត.ក តាំងពីការបង្កើតឡើងដំបូង និងបានផ្តល់ជំនួយថវិកាជិត ១លាន ដុល្លារនូវែលហ្សេឡង់ហើយ។ ជំនួយថវិកាលើកចុងក្រោយនេះ នឹងធ្វើឲ្យជំនួយសរុបរបស់ប្រទេសនូវែលហ្សេឡង់កើនដល់ ១.២ លាន ដុល្លារនូវែលហ្សេឡង់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ៣១៩
សារអេឡិកត្រូនិក: maeday@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh